# ប្រវត្តិស្ថាននាម បឹងទន្លេសាប និងទន្លេសាប

បណ្ឌិត ជិន សុជាតិ
មន្ត្រីស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រ នៃវិទ្យាស្ថានសិក្សាចិន
នៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០២២

តាមការសិក្សាលើប្រវត្តិនៃកម្ពស់នីវូសមុទ្រ យើងអាចទាញការសន្និដ្ឋានថា ក្នុងកំលុង៥០០០ឆ្នាំមុនបច្ចុប្បន្ន តំបន់ទំនាបកណ្តាលនៃប្រទេសកម្ពុជា រួមទាំងបឹងទន្លេសាប គឺស្ថិតនៅក្រោមបាតសមុទ្រ បន្ទាប់មកបឹងទន្លេសាប ក៏បានចាប់កំណើតឡើងនៅប្រហែល ៤០០០ឆ្នាំមកហើយ [1]។

រូបភាពបឹងទន្លេសាប



ប្រភព ៖ ផ្ទាំងគំនូរនៃអគារខេមរវិទូ(រាជបណ្ឌិត្យសភាកម្ពុជា)

បច្ចុប្បន្ននេះ អ្នកណាក៏គេស្គាល់ថា បឹងទឹកសាបដ៏ធំ ជាងគេមួយក្នុងតំបន់អាស៊ីអគ្នេយ៍នេះ មានឈ្មោះថា បឹងទន្លេសាប (Tonle Sap Lake) ដែលស្ថិតនៅចំកណ្តាលនៃប្រទេសកម្ពុជា។ ប៉ុន្តែមុននឹងយើងហៅបឹងនេះថា បឹងទន្លេសាប ឈ្មោះដើមរបស់ស្ថាននាមបឹងនេះគេហៅត្រឹមទន្លេសាប ប៉ុណ្ណោះ។ ហេតុនេះយើងនឹងធ្វើការសិក្សាលើប្រវត្តិស្ថាននាមទាំងពីរនេះថា តើវាក៏កើតឡើងតាំងពីពេលណាមក? ពាក្យបឹង ទន្លេ ស្ទឹង និងសមុទ្រ ប្រជាជាតិខ្មែរបានប្រើតាំងពីសម័យមុនអង្គរ ប៉ុន្តែគេមិនឃើញមានសម្ព័ន្ធពាក្យ ទន្លេសាប, បឹងទន្លេសាប, ទន្លេប្រែ, ឬសមុទ្រសាប ដែលប្រើក្នុងសិលា

---

[1] https://www.e-education.psu.edu/earth107/node/1496, Sea Level in the Past 200,000 Years

ចារឹក ឬឯកសារខ្មែរបុរាណណាមួយទេ ប៉ុន្តែគេឃើញមានសម្ព័ន្ធពាក្យ ទន្លេក្រៅ តាំងពីមុនសម័យអង្គរ ដែលទន្លេនេះគឺជាខ្សែទឹកមួយដែលបែកចេញពីទន្លេមេគង្គ ហើយយើងមិនអាចធ្វើសន្និដ្ឋានបានថា វាជាឈ្មោះដើមនៃទន្លេសាបបានដែរ[2]។

នៅសម័យចតុមុខ(១៤៣២-១៥២៧) គឺនៅពេលដែលកើតមានជម្លោះរវាងព្រះបាទ ច័ន្ទរាជា ដែលតាំងបន្ទាយនៅអម្រិន្ទបូរណ៍ (ស្រុកបរិបូរណ៍ ខេត្តពោធិសាត់) ដើម្បីធ្វើសង្គ្រាមជាមួយព្រះស្រីជេដ្ឋា (ស្តេចកន) គេឃើញមានប្រើពាក្យ **<u>ទន្លេសាប</u>** ក្នុងឆ្នាំ១៥១៦[3]។

ហេតុអ្វីបានខ្មែរហៅបឹងដ៏ធំនេះថាជា ទន្លេទៅវិញ បើផ្ទៃទឹកនេះធំដូចបឹង ឬសមុទ្រទៅហើយនោះ? ម្យ៉ាងទៀតម្តេចដាក់ឈ្មោះថា **<u>ទន្លេសាប</u>** បើពាក្យថា ទន្លេ ជាទូទៅមានន័យថា ទីផ្ទៃទឹកសាប ទៅហើយនោះ?

តាមរយៈវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួន ណាត ព្រះអង្គមានការសង្ស័យនិងសាកល្បងពន្យល់ថា ទន្លេសាប អាចមកពីពាក្យពីរបូកចូលគ្នា គឺពាក្យ ទន្លេ ដែលអាចក្លាយពាក្យសៀមថា ទះលេ៎(ทะเล) មានន័យថាសមុទ្រ (ព្រោះផ្ទៃទឹកធំណាស់មិនគួរប្រើត្រឹមពាក្យ ទន្លេទេ វាគួរហៅបឹង ឬសមុទ្រ ម្យ៉ាងទៀតអ្នកនៅជុំវិញបឹងទន្លេសាបមួយចំនួនក៏បានហៅត្រាប់តាមភាសាសៀមថា ទះលេ៎សាបផងដែរ)។ ចំណែកពាក្យ មួយទៀតគឺ សាប ជាពាក្យខ្មែរមានន័យថា មិនប្រៃ ដូច្នេះបើផ្គុំពាក្យពីរនេះចូលគ្នា ទន្លេសាប មានន័យថា សមុទ្រទឹកសាប។ យ៉ាងណាសម្តេចព្រះសង្ឃរាជ ជួន ណាត ព្រះអង្គក៏នៅមានការសង្ស័យបន្តទៀតថាបើពាក្យ ទន្លេ មកពីពាក្យសៀមថា ទះលេ៎(ทะเล) ម្តេចក៏សៀមមិនថា ទះលេ៎ចឺត(ทะเลจืด) ដែលមានន័យថា សមុទ្រសាប តាមភាសាសៀមម្តងទៅ ម្តេចក៏មានប្រើលាយឡំជាមួយពាក្យខ្មែរថា សាប។ ព្រះអង្គពន្យល់ទៀតថា បើសិនពាក្យ ទន្លេ មិនមែនក្លាយពីពាក្យទះលេ៎(ทะเล) របស់សៀមទេ បើខ្មែរប្រើពាក្យថា ទន្លេសាប វាគួរតែមានពាក្យ ទន្លេប្រៃ ទើបមានពាក្យ ទន្លេសាប។

ជាចុងក្រោយព្រះអង្គមិនបានកំណត់ថាពាក្យ ទន្លេសាប ជាពាក្យខ្មែរហៅ ឬមានឥទ្ធិពលពីសៀមឱ្យប្រាកដឡើយ ហើយព្រះអង្គក៏មិនបានបញ្ជាក់ថា ពាក្យនេះប្រើពីពេលណាមកដែរ។ ហេតុនេះតើមានការបកស្រាយថ្មីណាមួយទាក់ទងនឹងពាក្យ ទន្លេសាប នេះឬទេ?

---

[2] បណ្ឌិត មាឃ បូរ៉ា ប្រធានវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា។

[3] អេង សុត **មហាបុរសខ្មែរ ភាគ១** បោះពុម្ពឆ្នាំ១៩៩១ ទំព័រ ១២៩។

គួរបញ្ជាក់ថា ទោះបីខ្មែរយើងរកស្ថាននាម ទន្លេប្រៃ មិនទាន់ឃើញ ប៉ុន្តែខ្មែរក៏ធ្លាប់បានប្រើស្ថាននាម ស្ទឹងប្រៃ ផងដែរ នេះបើយោងលើសិលាចារឹកK.966 ដែលបានចារឡើងនាឆ្នាំ១១៦៧ នៃគ.ស. ។ ខ្មែរយើងធ្លាប់មានស្ថាននាម ស្ទឹងប្រៃ តែបច្ចុប្បន្ន មិនដឹងនៅទីណា? ទឹកដីសម័យអង្គរធំធេង ហើយស្ទឹងដែលនៅតាមឆ្នេរសមុទ្រ  មានច្រើនហើយអាចនិយាយថា ស្ទឹងប្រៃ ដែលខ្មែរធ្លាប់ហៅ បានបាត់ឈ្មោះក្នុងពេលណាមួយ ។

សំណួរសួរថា បើខ្មែរធ្លាប់ប្រើពាក្យ ស្ទឹងប្រៃ អញ្ចឹងវាគួរមាន ស្ទឹងសាប នៅទីណាមួយ ។ នៅលើផែនទីខេត្តកំពតសម័យដើមគេឃើញមានប្រើពាក្យ ព្រែកទឹកសាប (ពលរដ្ឋមួយចំនួននៅតំបន់នោះហៅព្រែកនេះថា ស្ទឹងទឹកសាប) ដែលស្ថាននាមនេះ គឺមានប្រើរហូតដល់បច្ចុប្បន្ន។

***ផ្នែកមួយនៃផែនទីខេត្តកំពត (ដើមទសវត្សរ៍ឆ្នាំ១៨៩០) និងផែនទី google map បច្ចុប្បន្ន***




ទាញតាមហេតុផលខាងលើ យើងអាចសន្និដ្ឋានថា ការប្រើស្ថាននាម ទន្លេសាប គឺជាសម្ព័ន្ធពាក្យភាសាខ្មែរ ហើយក្នុងអតីតកាលខ្មែរប្រាកដជាធ្លាប់មានប្រើស្ថាននាម ទន្លេប្រៃ នៅទីណាមួយជាក់ជាពុំខាន(តាមការសន្និដ្ឋាន ទន្លេប្រៃ អាចស្ថិតក្នុងតំបន់អតីតទឹកដីកម្ពុជាក្រោម ហើយយើងលែងប្រើស្ថាននាមទន្លេប្រៃ ចាប់តាំងពីដែនដីទាំងនេះបានរបូតចេញពីការគ្រប់គ្រងរបស់ខ្មែរ)។ យើងហាក់មានជំនឿថានៅពេលវេលាណាមួយក្នុងអតីតកាល ទន្លេបាសាក់ អាចមានទីផ្សារទឹកប្រៃនៅផ្នែកណាមួយ ក្នុងទឹកដីវៀតណាមខាងត្បូងសព្វថ្ងៃ។ តាមការសិក្សាលើស្ថាននាមតាមដងទន្លេបាសាក់ មានស្ថាននាមមួយឈ្មោះថា ព្រែកអំបិល ។ ស្ថាននាមនេះធ្វើឱ្យយើងដាក់ជាសំណួរថា ទន្លេបាសាក់មានផ្សារទឹកសាបសព្វថ្ងៃ ម្តេចក៏មានស្ថាននាម ព្រែកអំបិល(ទឹកប្រៃ)នៅតាមដងទន្លេនេះ?

### *ផែនទី google map បច្ចុប្បន្នបង្ហាញពីឈ្មោះព្រែកអំបិល*




*យើងមានភស្តុតាងមួយទៀត ដែលយើងយល់ថា មិនមានឥទ្ធិពលពីភាសាសៀមនោះគឺ ក្នុងរជ្ជកាលព្រះបាទ ច័ន្ទរាជា នាសម័យលង្វែកគឺក្នុងកំឡុងពាក់កណ្ដាលស.វ.ទី១៦ ពេលព្រះអង្គយាងទៅជួសជុលប្រាសាទតំបន់អង្គ ព្រះអង្គបានចារសិលាចារឹកនៅអង្គរវត្ត ដែលមានប្រើពាក្យថា* ***<u>ទនលេហសាប្ប</u>*** [4] *(ទន្លេសាប) ។*

### *អត្ថបទនៃសិលាចារឹកនគរវត្ត*



លេខ ១៧

nº 17 (B)

(១) សត្តម្មស្តុសំម្ពត្តីតីរេក ១៥៥០ សក្ខរោងអ្នក្សត្រ(២) ទៃហបុស ៦ រោជ ប៉ើ្វយសោរិពារសារតា ជុំនុំមហ្វោ (៣) វិពោរិ តាមាន នូហ្វោរិព្រិហ្មាតាំបុស នូហ្វោរិសុក្ខតាំទេ (៤) ព្ត តិស្ស ទិំងអំប្យាលនេះមោកអំម្ហ៊ីយបណ្តាយព្រៃដ្ឋ (៥) ផ្លូង<u>ទនលេហសាប្ប</u>ខ្យហខ្យលកកេប្យកកាប្យអាភ (៦) ញាព ទេព្វប្រិ្វមោក

*តាមសម្ព័ន្ធពាក្យ* ***<u>ទនលេហសាប្ប</u>*** *បញ្ជាក់ថា សម្លេងប្រកបក្នុងសម្ព័ន្ធពាក្យនេះ ខ្មែរមិនមានទំនោរចម្លងសម្លេងភាសាសៀម* ทะเล*(ទះល៉េ) នោះទេ។ ហេតុនេះពាក្យ ទន្លេសាប គឺជាពាក្យភាសាខ្មែរ ដែលពាក្យ ទន្លេ*(River) *មិនមានន័យថា សមុទ្រសាប ឬសមុទ្រទឹកសាបទេ។ យើងមានការ*

---

[4] Mahā Bidūr Krassem, *សិលាចារឹកនគរវត្ត*, មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ, ១៩៨៣។

ទទួលស្គាល់ថា បឹងទឹកសាបនេះ មានពលរដ្ឋខ្មែរមួយចំនួន បានហៅ ទន្លេសាប ស្រដៀងនឹងភាសាសៀមថា ថះលេសាប ឬទះលេសាប ។ ការហៅនេះទំនងជាកើតឡើងចាប់ ពីរជ្ជកាលក្សត្រសៀមព្រះនាមពញាតាក(ពញាតាស៊ីន) បានប្រើប្រាស់ទ័ពជើងទឹកឆ្លងកាត់ទន្លេសាបជាលើកដំបូងដើម្បីធ្វើសង្គ្រាមជាមួយខ្មែរនា ឆ្នាំ១៧៦៩[5]និងឆ្នាំជាបន្តបន្ទាប់មកទៀត។

ក្រោយមកទៀតក្នុងកំឡុងពេលដែលខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ្ឌ (បន្ទាយមានជ័យ) បានស្ថិតនៅក្រោមការគ្រប់របស់សៀមពីឆ្នាំ១៨៦៧ ដល់ឆ្នាំ១៩០៧ និងនៅរវាងឆ្នាំ ១៩៤១ ដល់ឆ្នាំ១៩៤៦[6] គឺជាដំណាក់កាលដែលព្រំដែនសៀមនៅជាប់នឹងបឹងទឹកសាបដ៏ធំនេះ ហេតុនេះ ពលរដ្ឋខ្មែរដែលរស់នៅក្រោមការគ្រប់គ្រងរបស់សៀមក៏បានហៅ ទន្លេសាប ថា ទះលេសាប តាមសម្លេងភាសាសៀមផងដែរ។

**ផែនទីខ្មែរ-សៀមចន្លោះឆ្នាំ១៨៦៧ ដល់ឆ្នាំ១៩០៧**




នៅក្នុងការចងចាំភូមិសាស្ត្រ ឬកំណត់ត្រារបស់ប្រជាជាតិខ្មែរពាក្យថា ទន្លេសាប ដែលខ្មែរប្រើនៅសម័យក្រោយអង្គរនោះ គឺសម្គាល់ហៅទាំងបឹងទឹកសាបដ៏ធំនេះផង រួមគ្នាជាមួយនឹងទន្លេសាបបច្ចុប្បន្ននេះផង ។

[5] រាជបណ្ឌិត្យសភាកម្ពុជា, កាលប្រវត្តិសាស្ត្រកម្ពុជា ពីការកកើតអរិយធម៌ដល់ឆ្នាំ១៩៩៣, ឆ្នាំ២០២១។

[6] -ដ- ។

### ***ផែនទីបឹងទន្លេសាប និងទន្លេសាប ដែលខ្មែរហៅរួមគ្នាថា ទន្លេសាប***




*មុននេះយើងសិក្សាលើស្ថាននាម ទន្លេសាប ឥឡូវយើងងាកមកស្វែងយល់ពីការប្រើស្ថាននាម បឹងទន្លេសាប ម្តងវិញ តើបឹងទន្លេសាប (ផ្ទៃទឹកគិតពីឆ្នុកទ្រូ ទៅដល់ទល់នឹងស្ទឹងមង្គលបុរី) ត្រូវបានគេហៅថាបឹងទន្លេសាបពីពេលណាមក?*

*នៅក្នុងភាសាបរទេសបានហៅ ទន្លេសាប ថាជា បឹង ដែលយើងរកឃើញដំបូងបំផុតនៅលើផែនទីរបស់លោក ជេរ៉ា ឌឺ ហ្សូដ៍* Gerard de Jode( *ជាជនជាតិហូឡង់) ដែលបានគូសនៅឆ្នាំ១៥៥៩ និងបោះពុម្ពនៅទីក្រុងអែនថ្វើប* Antwerp *ប្រទេសបែលហ្ស៊ិក នាឆ្នាំ១៥៩៨ ។*

**ផែនទី Gerard de Jode/Antwerp / 1593**




*ប្រភព ៖ Antique map of Southeast Asia*

នៅលើផែនទីនោះក្នុងដែនដីកម្ពុជា គេសរសេរថា Regno de Campoia ដែលមានន័យថា ដែនដីកម្ពុជា។ នៅលើដែនដីនោះក៏បានបង្ហាញពីបឹងមួយដ៏ធំ ដែលនៅលើបឹងនោះគេសរសេរថា Lago de çã(Cã?) baio។ លោក ជេរ៉ា ឌឺ ហ្សូដ៍ (Gerard de Jode) មិនបានហៅបឹងនេះថា សមុទ្រ ឬទន្លេ ទេ គឺ ហៅថា បឹង(Lago)ដែលមានឈ្មោះថា çã baio ។

**ផែនទី <u>Gerard de Jode</u>បង្ហាញពីដែនដីកម្ពុជា និងបឹងធំមួយឈ្មោះ çã(Cã?) baio**




ចាប់ពីពេលនោះកន្លងមករាប់រយឆ្នាំមកទៀតផែនទីពួកអឺរ៉ុបជាច្រើនបានគូស និងបោះពុម្ពផ្សាយជាបន្តបន្ទាប់ ប៉ុន្តែមិនបានបង្ហាញអំពីរូបភាពបឹងទន្លេសាបទេ មានន័យថា ពួកគេមិនបានចូលជ្រៅដល់តំបន់ផ្ទៃក្នុងកម្ពុជានោះឡើយ។ ខាងក្រោមជាផែនទីខ្លះៗសម្រាប់លើកជាឧទាហរណ៍ ដែល បង្ហាញថា ផែនទីពួកគេមិនមានគូសអំពីបឹងទន្លេសាបទេ។




*ប្រភព ៖ Antique map of Southeast Asia*

រហូតដល់ឆ្នាំ១៨៣៨ ទើបយើងឃើញមានផែនទីរបស់លោក ហ្សង់ លួី តាបឺដ Jean-Louis Taberd ជាជនជាតិបារាំង ដែលបានគូសបង្ហាញរូបរាងបឹងទន្លេសាបនៅក្នុងស្នាដៃរបស់គាត់ស្តីពី វចនានុក្រម ឡាតាំង-វៀតណាម (Latin-Vietnamese dictionary) ដែលបានបោះពុម្ពនាឆ្នាំ ១៨៣៨ ។

**ផែនទីអណ្ណាមឆ្នាំ១៨៣៨**




ប្រភព ៖ Jean-Louis Taberd, Latin-Vietnamese dictionary, 1838.

ផែនទីនេះ ធ្វើឡើងក្នុងកំឡុងពេលដែលអណ្ណាម មានឥទ្ធិពលអំណាចលើប្រទេសកម្ពុជា ហេតុនេះនៅលើបឹងទឹកសាបនោះ លោកបានសរសេរជាភាសាបារាំងថា Magnus Lacus និងបកជាភាសាវៀតណាមថា Biển hồ ដែលមានន័យជាភាសាខ្មែរថា **បឹងសមុទ្រ** ។

ផែនទីបឹងទឹកសាបនៅកណ្ដាលប្រទេសកម្ពុជា បង្ហាញរូបរាងកាន់តែច្បាស់ជាងមុននិងការហៅឈ្មោះត្រាប់តាមភាសាខ្មែរបានល្អជាងមុន គឺតាមរយៈផែនទីរបស់ ហង់រី មូហូត( Henri Mouhod) ដែលលោកបានឆ្លងកាត់ប្រទេសកម្ពុជាក្នុងកំឡុងឆ្នាំ១៨៥៩-១៨៦០។ នៅលើបឹងទឹកសាបដ៏ធំនេះ លោកបានសរសេរថា L. Tonle ou Tonli Sap ដែលមានន័យថា បឹងទន្លេ ឬ ទន្លេសាប។

**ផ្នែកមួយនៃផែនទីរបស់លោក ហង់រី មូហូត( Henri Mouhod)**




ប្រភព ៖ Erhard and Bonaparte, publ. on le Tour du Monde, Paris, 1863

នៅក្នុងឆ្នាំ១៨៨១ តាមរយៈផែនទី Carte de L'indo-chin Oriental បានបង្ហាញអំពីផែនទីបឹងទឹកសាប ដោយចែកជាពីរតំបន់គឺ Grand Lac ou Tonlé Sap និង Petit Lac (បឹងតូច)។ ជាចំណុចចាប់អារម្មណ៍នោះ បារាំងព្យាយាមសរសេរឈ្មោះបឹងទឹកសាបនេះថា Tonlé Sap (ទន្លេសាប) គឺហៅតាមខ្មែរ មានន័យថា ខ្មែរមិនហៅបឹងទឹកសាបនេះថា បឹងទន្លេសាប ទេ ទោះបីបារាំងព្យាយាមហៅទន្លេសាប ថាជាបឹង(Lac) ក៏ដោយ។

**ផែនទី Carte de L'indo-chin Oriental, 1881**





*តាមការសិក្សាលើប្រវត្តិសាស្ត្រកម្ពុជា ក្នុងរបបអាណាព្យាបាលបារាំង ក្នុងដំណាក់កាលដំបូង ពួកគេនៅមិនទាន់ស្គាល់ភូមិសាស្ត្រខ្មែរឱ្យបានល្អិតល្អន់ទេ ហេតុនេះបារាំងបានចាប់ផ្តើមឱ្យជនម្ចាស់ស្រុកធ្វើជំរឿនផែនទីជាភាសាខ្មែរនៅក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៨៨០ បន្ទាប់ពីនោះមក បារាំងអាចកំណត់ស្ថាននាមនានានៃភូមិសាស្ត្រកម្ពុជា ដោយសរសេរជាអក្សរបារាំង និងបានចាប់ផ្តើមរៀបចំគ្រប់គ្រងរដ្ឋបាលដែនដីនៅទូទាំងប្រទេសកម្ពុជា ចាប់ពីឆ្នាំ១៩០០*[7] ។

**ឧទាហរណ៍ ផែនទីតំបន់ខេត្តខ្សាច់កណ្តាល**



*ប្រភព៖* http://ltocambodia.blogspot.com/2011/08/old-maps-kampot.html

*ទោះបីយើងមិនទាន់មានផែនទីគូសដោយជនម្ចាស់ស្រុក យកមកបង្ហាញក្នុងតំបន់បឹងទន្លេសាប នាទសវត្សរ៍ឆ្នាំ១៨៨០នោះ ក៏យើងអាចបញ្ជាក់ថា ជនម្ចាស់ស្រុកនៅតែហៅស្ថាននាមបឹងទឹកសាបនោះថា **ទន្លេសាប** គឺមិនហៅតាមបារាំងថា **បឹងទន្លេសាប** ទេ។ ហេតុនេះហើយ នៅលើផែនទីដែលបង្កើតឡើងដោយរបបអាណាព្យាបាលបារាំង គឺតែងតែបញ្ជាក់ស្ថាននាមបឹងទឹកសាបនេះជាពីរប្រភេទគឺ បឹងធំ*(Grand Lac) *ឬ ទន្លេសាប* (Tonlé Sap)។

[7] *រាជបណ្ឌិត្យសភាកម្ពុជា, កាលប្រវត្តិសាស្ត្រកម្ពុជា , ដ.ឯ.ម ។*

## ផែនទីសម័យអាណាព្យាបាលបារាំងនៅកម្ពុជា បង្ហាញពី
## បឹងធំ(Grand Lac) ឬ ទន្លេសាប (Tonlé Sap)




នៅឆ្នាំ១៩១៥ បារាំងចេញច្បាប់ចាត់តាំងឱ្យមេឃុំនីមួយៗ ទារពន្ធនៅក្នុងឃុំដែលខ្លួនគ្រប់គ្រង ម្យ៉ាងទៀតតាមព្រះរាជប្រកាសចុះថ្ងៃទី១៦ ខែមករា ឆ្នាំ ១៩១៥ បារាំងក៏បានចេញច្បាប់ស្តីពីការទារពន្ធនេសាទក្នុងទន្លេ និង សមុទ្រទូទាំងប្រទេសកម្ពុជា[8] អាជ្ញាធរបារាំងបានធ្វើការកំណត់ដែនដីយកពន្ធ និងបានបែងចែកតំបន់យកពន្ធទៅតាមផែនទីរបស់ខ្លួនៗ ការអនុវត្តពន្ធនេះចាប់ផ្តើមនៅឆ្នាំ១៩១៧[9]។

ចាប់ពីឆ្នាំ១៩១៧ បើទោះបីនៅលើផែនទីមិនទាន់មានប្រើពាក្យ **បឹងទន្លេសាប** ជាភាសាខ្មែរ ប៉ុន្តែការអនុវត្តការងារគ្រប់គ្រងដែនដីរដ្ឋបាល និងការអនុវត្តពន្ធតាមការចង្អុលបង្ហាញពីពួកបារាំង អាជ្ញាធរខ្មែរមួយចំនួនចាប់ផ្តើមហៅ **ទន្លេសាប** ថា **បឹងទន្លេសាប** តាមរបបរាយការណ៍របស់ខ្លួនជូនទៅអាជ្ញាធរបារាំង ក្នុងខណៈដែលប្រជារាស្ត្រខ្មែរសាមញ្ញ ភាគច្រើននៅតែបន្តហៅបឹងទឹកសាបដ៏ធំនេះត្រឹមថា **ទន្លេសាប** រហូតមកដល់សព្វថ្ងៃ។

គួរបញ្ជាក់ថា ផែនទីផ្លូវការរបស់ប្រទេសកម្ពុជាទាំងអស់គឺផលិតឡើងដោយពួកបារាំងដែលមានជំនាញខាងផែនទី ហេតុនេះបើយើងពិនិត្យលើផែនទីបោន (BONNE) ដែលធ្វើឡើងតាំងពីឆ្នាំ

---

[8] រាជបណ្ឌិត្យសភាកម្ពុជា, កាលប្រវត្តិសាស្ត្រកម្ពុជា , ដ.ឯ.ម ។

[9] រាជកិច្ចឆ្នាំទី០៧ លេខ០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩១៧

*១៩៣៣ ដល់ឆ្នាំ១៩៥៤ ការប្រើស្ថាននាមតាមភាសាខ្មែរនៅលើផែនទី តែសរសេរជាអក្សរឡាតាំងទាំងអស់ មិនមានប្រើអក្សរខ្មែរទេ*[10]*។ អ្នកជំនាញខាងផែនទីភូមិសាស្ត្រលើកឡើងទៀតថា ក្នុងសម័យសង្គមរាស្ត្រនិយមផែនទីផ្លូវការក៏នៅតែប្រើផែនទីបោនដដែល។*

*ក្រោយឯករាជ្យផែនទីប្រើប្រាស់ផ្ទៃក្នុងចាប់ផ្តើមដាក់ស្ថាននាមជាអក្សរ និងភាសាខ្មែរ បន្ថែមពីលើផែនទី ដែលប្រើស្ថាននាមអក្សរឡាតាំង ហើយកិច្ចការនេះត្រូវបានធ្វើឱ្យប្រសើរថែមទៀតតាមរយៈជំនួយសហរដ្ឋអាម៉េរិកក្នុងការធ្វើជំរឿនស្ថាននាមនៅលើផែនទីបោនឱ្យទៅជាភាសា និងអក្សរខ្មែរចាប់ពីឆ្នាំ១៩៦២*[11]*។ ក្រោយមកទៀត នាឆ្នាំ១៩៧១ សហរដ្ឋអាម៉េរិកបានបោះពុម្ពផែនទីយូធីអឹម* (UTM) 1/500 000*ដែលបំលែងពីផែនទីបោន* (BONNE) 1/100 000*។ នៅលើផែនទីយូធីអឹមនេះ គឺមានប្រើទាំងអក្សរខ្មែរ និងអក្សរឡាតាំងនៅលើផែនទី ដែលសព្វថ្ងៃកម្ពុជា ប្រើជាផែនទីនេះផ្លូវការ។*

*ការពន្យល់ខាងលើនេះចង់បង្ហាញថា តាមរយៈផែនទីយូធីអឹម ដែលបោះពុម្ពឆ្នាំ១៩៧១ ការប្រើស្ថាននាម* ***បឹងទន្លេសាប*** *ជាអក្សរខ្មែរនៅលើផែនទីត្រូវបានកំណត់ជាផ្លូវការ។*

***ផែនទីយូធីអឹម* (UTM) *របស់សហរដ្ឋអាម៉េរិកបង្ហាញពីតំបន់ឆ្នុកទ្រូ និងបឹងទន្លេសាប***




*យ៉ាងណាក៏ដោយមកដល់សព្វថ្ងៃនេះ បឹងទឹកសាបដ៏ធំនេះក្នុងភាសានិយាយធម្មតា ប្រជាជនខ្មែរនៅជុំវិញបឹងនេះនៅតែហៅថា* ***ទន្លេសាប*** *ក្នុងខណៈស្ថាននាមផ្លូវការគឺ* ***បឹងទន្លេសាប*** *។/*

---

[10] *ឯកឧត្តមបណ្ឌិត យង់ ពៅ អគ្គលេខាធិការ នៃរាជបណ្ឌិត្យសភាកម្ពុជា។*

[11] *តឹក មេង, ជិន សុជាតិ,* ***ប្រវត្តិសេដ្ឋកិច្ចកម្ពុជា****, រាជបណ្ឌិត្យសភាកម្ពុជា, ឆ្នាំ២០១៧។*